00595530

E 188/6

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

កាលបរិច្ឆេទឯកសារ: ២៤ សីហា ឆ្នាំ២០១០

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី ២

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និងខ្មែរ (បកប្រែ)

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24/08/2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ៖

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះ

អាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 24/08/2010
ម៉ោង (Time/Heure): 9:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**(ក្រុមទី ២)**

---

ដាក់ដោយ៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

ផ្ញើជូន៖

អង្គជំនុំជម្រះសាលាដំបូង

ចៅក្រម នីល នុន ប្រធាន

ចៅក្រម S. CARTWRIGHT

ចៅក្រម យ៉ា សុខន

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម

ចៅក្រម សោម សេរីវុឌ្ឍន៍

ចៅក្រម ស៊ិន វិទ្ធិ

ចៅក្រម យ៉ា ណារិន

ចៅក្រម Motoo Noguchi

ចៅក្រម Agniezska KLONOWIECKAMILART

ចៅក្រម Chandra Nihal Jayasinghe

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ ហៅ “ឌុច”

ចៅក្រម J-M. LAVERGNE

ចៅក្រម ធូ មុន្នី

**សហមេធាវីការពារក្ដីជនជាប់ចោទ៖** E 188/6

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**មេធាវីតំណាងភាគីដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Phillipe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Pierre-Oliver SUR

លោកស្រី ទី ស្រ៊ីនណា

លោក Karim Khan

លោក Alain WERNER

លោកស្រី Brianne McGONIGLE

លោកស្រី Fabienne TRUSSES-NAPRUS

លោកស្រី Christine MARTINEAU

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី ២ សូមដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង (វិ.លើកទី ៣) ជំនួសមុខឱ្យអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ លោកស្រី ណាំ ម៉ុន (E2/32) លោកស្រី ឆាយ កន *ហៅ* លៀង កន (E2/35) លោកស្រី ហុង សាវ៉ាត (E2/83) លោក ឈឹម ស៊ីថា (E2/22) និងលោកស្រី ញ៉ិប គីមស្រ៊ា (E2/64) ត្រង់ចំណុចនៃការបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ្នកទាំងនេះ។ អនុលោមតាមវិធាន ១០៥(៣) និងវិធាន ១០៥(២)(ក) និង(គ) នៃវិធានផ្ទៃក្នុង មូលដ្ឋាននៃ បណ្តឹងសាទុក្ខត្រូវបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនេះ។

យើងខ្ញុំបានដាក់ភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សរ ដែលបានអនុញ្ញាតឱ្យប្តឹងសាទុក្ខ។

## ក. សេចក្តីសង្ខេបអំពីមូលដ្ឋាននៃបណ្តឹងសាទុក្ខ

### I. មូលដ្ឋានទី ១

*ការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/32, E2/35, E2/83, E2/22 និង E2/64 បានធ្វើឡើងដោយផ្អែកលើការភ័ន្តច្រឡំនៃអង្គច្បាប់/វិធានផ្ទៃក្នុង ដែលនាំឱ្យសាលក្រមនេះ មោឃៈ ដោយហេតុថាមានការរំលោភបំពានលើវិធាន ២១(១) វិធាន ២១(១)(ក), វិធាន ២១(១)(គ) វិធាន ២៣(៤) វិធាន ៨៣(១) និងវិធាន ១០០ នៃវិធានផ្ទៃក្នុង។*

១. អង្គជំនុំជម្រះគួរច្រានចោលការបដិសេធលើការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថា អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គច្បាប់/វិធានផ្ទៃក្នុង នៅពេល អ.ជ.ស.ដ ចេញសេចក្តីសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីជាពីរដំណាក់កាលនៅក្នុង សាលក្រម[១]។ វិធានផ្ទៃក្នុង និងយុត្តិសាស្ត្រអន្តរជាតិ មិនផ្តល់មូលដ្ឋានក្នុងការចេញសេចក្តីសម្រេច ដូច្នេះឡើយ។

### II. មូលដ្ឋានទី ២

*ការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/32, E2/35 និង E2/83 បានធ្វើឡើងដោយផ្អែកលើការភ័ន្តច្រឡំនៃអង្គច្បាប់/វិធានផ្ទៃក្នុង ដែលនាំឱ្យសាលក្រមនេះ មោឃៈ ហើយការបដិសេធនេះជាការរំលោភបំពានលើវិធាន ២៣(៥) នៃវិធានផ្ទៃក្នុង (វិ. លើកទី៣) ដោយហេតុថាបានអនុវត្តដោយមិនត្រឹមត្រូវលើបទដ្ឋាននៃការបង្ហាញភ័ស្តុតាង។*

---

[១] សាលក្រម កថាខណ្ឌ ៦៣៥ កថាខណ្ឌ ៦៣៦ កថាខណ្ឌ ៦៣៧។

២. អ.ជ.ស.ដ បានអនុវត្តដោយមិនត្រឹមត្រូវលើបទដ្ឋាននៃការបង្ហាញភ័ស្តុតាង ដែលជាហេតុនាំឱ្យខ្លួនបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[២]។ តាមពិត អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបំពេញបទដ្ឋាននៃការបង្ហាញភ័ស្តុតាង ដូចមានចែងនៅក្នុងវិធាន ២៣(៥) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះអ្នកទាំងនេះបានដាក់ចម្លើយ និងរូបថតនៅសារមន្ទីរទួលស្លែងដែលសម្គាល់សមាជិកគ្រួសាររបស់ពួកគេ។ ការអនុវត្តដោយមិនត្រឹមត្រូវលើបទដ្ឋាននៃការបង្ហាញភ័ស្តុតាងគឺជាការភ័ន្តច្រឡំលើអង្គច្បាប់ដែលនាំឱ្យសាលក្រមត្រង់ចំណុចនៃការបដិសេធមិនទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី មោឃៈ។

III. មូលដ្ឋានទី ៣

*ការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/83 បានធ្វើឡើងដោយផ្អែកលើការភ័ន្តច្រឡំនៃអង្គហេតុ ដែលនាំឱ្យមានការភ័ន្តច្រឡំលើការសម្រេចសេចក្តីរបស់តុលាការ ដោយហេតុថាមិនបានពិនិត្យមើលរូបថតជនជាប់ឃុំឃាំងដែលជាជនរងគ្រោះផ្ទាល់ ដែលរូបថតនេះបានដាក់ជូនរួចហើយ។*

៣. អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គហេតុ នៅពេលមិនបានពិនិត្យមើល ឬ មិនយកចិត្តទុកដាក់លើរូបថត ឡឹក ស្រេង ដែលគេថតនៅទួលស្លែង ហើយដែលលោក ឡឹក ស្រេង នេះ ជាខ្មោចឪពុកមារបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ លោកស្រី ហុង សាវ៉ាត ដែលត្រូវបានតុលាការបដិសេធមិនទទួលស្គាល់។ អ.ជ.ស.ដ បានសន្និដ្ឋានថា លោកស្រី ហុង សាវ៉ាត មិនបានដាក់ឯកសារភ័ស្តុតាងអ្វីផ្សេងក្រៅពីចម្លើយរបស់លោកស្រី[៣]។ ប៉ុន្តែ តាមការពិត លោកស្រីបានដាក់រូបថត។

IV. មូលដ្ឋានទី ៤

*ការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/64, E2/22 និង E2/83 បានធ្វើឡើងដោយផ្អែកលើការភ័ន្តច្រឡំនៃអង្គច្បាប់/វិធានផ្ទៃក្នុងដែលនាំឱ្យសាលក្រម មោឃៈ ដោយហេតុថាបានរំលោភបំពានវិធាន ២៣(២) នៃវិធានផ្ទៃក្នុង នៅពេលទាមទារលក្ខខណ្ឌនៃ "ចំណងពិសេសនៃសេចក្តីស្រឡាញ់"។*

៤. អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គច្បាប់នៅពេលខ្លួនរកឃើញថាមិនមាន "ចំណងពិសេសនៃសេចក្តីស្រឡាញ់" រវាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/83, E2/22 និង

---

[២] សាលក្រម កថាខណ្ឌ ៦៣៦ កថាខណ្ឌ ៦៤៦ កថាខណ្ឌ ៦៤៨។

[៣] សាលក្រម កថាខណ្ឌ ៦៤៨។

00595534

E188/6



E2/64 និងបុគ្គលនីមួយៗដែលបានបាត់បង់ជីវិត[៤]។ ការរកឃើញដូច្នេះជាការភ័ន្តច្រឡំលើអង្គច្បាប់ពីព្រោះវាជាការបកស្រាយដោយភ័ន្តច្រឡំលើវិធាន ២៣(២) នៃវិធានផ្ទៃក្នុង ដែលវិធាននេះមិនមានចែងលក្ខខណ្ឌ ឬក៏បញ្ញត្តិលើកឡើងអំពី "ចំណងពិសេសនៃសេចក្តីស្រឡាញ់"។ ការភ័ន្តច្រឡំលើអង្គច្បាប់ដូច្នេះ នាំឱ្យការបដិសេធមិនទទួលស្គាល់លើដើមបណ្តឹងរដ្ឋប្បវេណី មោឃៈ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលគួរច្រានចោលការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យទាំងបីរូប ជាដើមបណ្តឹងរដ្ឋប្បវេណី។

## V. សេចក្តីសន្និដ្ឋាន

៥. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងដាក់មូលដ្ឋានពេញលេញនៃបណ្តឹងសាទុក្ខ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងដោយសង្ខេបលើបណ្តឹងសាទុក្ខនេះ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងស្នើសុំឱ្យ៖

- ប្រកាសទទួលយកបណ្តឹងសាទុក្ខនេះ។
- ទទួលយកឯកសារគាំទ្របន្ថែម។
- ច្រានចោលដីកាសម្រេចបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រួមមាន លោកស្រី ណាំ ម៉ុន (E2/32) លោកស្រី ឆាយ កន *ហៅ* លៀង កន (E2/35) លោកស្រី ហុង សាវ៉ាត (E2/83) លោក ឈឹម ស៊ីថា (E2/22) និងលោកស្រី ញ៉ិប គីមស្រ៊ាំ (E2/64) ហើយទទួលស្គាល់អ្នកទាំងនេះជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ វិញ។

| | |
|---|---|
| លោក ហុង គឹមសួន | លោក គង់ ពិសី |
| លោក យ៉ុង ផានិត | កញ្ញា Silke STUDZINSKY |

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ។

[៤] សាលក្រម កថាខណ្ឌ ៦៤៣ កថាខណ្ឌ ៦៤៨។